**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

**លេខ**.......................

# សេចក្តីប្រកាសព័ត៌មាន

តបតាមការអញ្ជើញរបស់ **សម្តេចពិជ័យសេនា ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ គណៈប្រតិភូយោធាជាន់ខ្ពស់ហ្វីលីពីន ដឹកនាំដោយ **ឯកឧត្តម រីខាដូ អេ ដាវីដ ជូរ** (Ricardo A David JR) អនុរដ្ឋមន្ត្រីក្រសួងការពាជាតិ ហ្វីលីពីន នឹងអញ្ជើញមកបំពេញទស្សនកិច្ចមិត្តភាព និងផ្លូវការរយៈពេល០៤ថ្ងៃ **ចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩** នៅព្រះរាជាណាចក្រកម្ពុជា ។

ក្នុងដំណើរបំពេញទស្សនកិច្ចនេះ គណៈប្រតិភូយោធាជាន់ខ្ពស់ហ្វីលីពីន នឹងអញ្ជើញចូលរួមកិច្ចប្រជុំទ្វេភាគីស្តីពីគណៈកម្មាធិការសហប្រតិបត្តិការយោធារួមគ្នា (JDCC) កម្ពុជា-ហ្វីលីពីន ដែលកិច្ចប្រជុំនេះនឹងប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម នាយឧត្តមសេនីយ៍ នាង ផាត** រដ្ឋលេខាធិការប្រចាំការក្រសួងការពារជាតិ និង**ឯកឧត្តម រីខាដូ អេ ដាវីដ ជូរ** (Ricardo A David JR) អនុរដ្ឋមន្ត្រីក្រសួងការពាជាតិ នាទីស្តីការក្រសួងការពារជាតិ។

បន្ទាប់មក**ឯកឧត្តម រីខាដូ អេ ដាវីដ ជូរ** (Ricardo A David JR) ព្រមទាំងប្រតិភូយោធាជាន់ខ្ពស់ ហ្វីលីពីន នឹងចូលជួបសំដែងការគួរសម សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិផងដែរ នៅវិមានមិត្តភាព ទីស្តីការគណៈរដ្ឋមន្ត្រី ៕

*ថ្ងៃសៅរ៍ ៤កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២*

រាជធានីភ្នំពេញ, ថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៩

វិថីហ្សកឌឺមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖០២៣ ៨៨៣ ២៧៤ អ៊ីម៉ែល៖ generalsec@mod.gov.kh